ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jun-2021, 15:09
CMS/CFO: Sann Rada

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សេរីវុឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Maureen HARDING CLARK** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២១** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ:** |

# សេចក្ដីសម្រេចលើសំណើសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំការពន្យារពេលសវនាការលើបណ្ដឹងសាទុក្ខ និងសេចក្ដីបង្គាប់ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទសវនាការនាបណ្ដឹងសាទុក្ខ

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**សហព្រះរាជអាជ្ញា**

ជា លាង

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីការពារក្ដី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Brenda HOLLIS

**<u>ការិយាល័យរដ្ឋបាល</u>**

ក្រាញ់ តូនី

Knut Rosandhaug

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("តុលាការកំពូល" និង "អ.វ.ត.ក") បានទទួលសំណើរបស់សហមេធាវីនាំ មុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំផ្អាកសវនាការបណ្តឹងសាទុក្ខដែលបានគ្រោងធ្វើឡើងនៅថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ ("សំណើសុំពន្យារពេល")[1] ។ សេចក្តីសម្រេចនេះនឹងលើកពីមូលហេតុ ដែលធ្វើឱ្យអង្គជំនុំជម្រះសម្រេចពន្យារពេលសវនាការបណ្តឹងសាទុក្ខ("សវនាការ") កំណត់កាលបរិច្ឆេទថ្មី សម្រាប់សវនាការ និងផ្តល់សេចក្តីណែនាំ និងសេចក្តីលម្អិតពាក់ព័ន្ធទៅនឹងទម្រង់បែបបទសវនាការដែល នឹងត្រូវធ្វើឡើង។

## I. **សាវតារ**

1. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងទោសនៅក្នុង សំណុំរឿង ០០២/០២ តាមរយៈការចេញសេចក្តីសង្ខេបនៃការយល់ឃើញ និងផ្នែកសម្រេចសេចក្តីនៃ សាលក្រមដោយផ្ទាល់មាត់ និងក្រោយមកបានជូនដំណឹងសាលក្រមជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៩ ("សាលក្រមអង្គជំនុំជម្រះសាលា ដំបូង")[2]។

2. នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹង សាលក្រមអង្គជំនុំជម្រះសាលាដំបូង[3] ដែលត្រូវបាន ខៀវ សំផន ធ្វើការឆ្លើយតបនៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩[4]។ នៅថ្ងៃទី ២៧ ខែ កម្ភៈ ឆ្នាំ ២០២០ ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាល

---

[1] សំណើរបស់សហមេធាវីនាំមុខសុំពន្យារពេលសវនាការបណ្តឹងសាទុក្ខគ្រោងធ្វើថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F61។

[2] ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រតិចារិកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465។

[3] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50។

[4] សារណាតបរបស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F50/1។

ក្រុមអង្គជំនុំជម្រះសាលាដំបូង[5] ដែលត្រូវបានឆ្លើយតបដោយសហព្រះរាជអាជ្ញា[6] និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី("សហមេធាវីនាំមុខ")[7] នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ និងថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ រៀងៗខ្លួន (ជារួមហៅថា "ភាគី")។

3. នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ យោងតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះបានជូនដំណឹងភាគីថា អង្គជំនុំជម្រះនឹងបើកសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ ("សវនាការ") ចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២១ និងថា ដីកាកំណត់កាលបរិច្ឆេទនឹងត្រូវចេញក្នុងពេលសមស្រប[8]។

4. នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១ អង្គជំនុំជម្រះបានចេញដីកាចាត់តាំងចៅក្រមរបាយការណ៍សម្រាប់សវនាការ[9] និងការអញ្ជើញភាគីដាក់សេចក្តីសង្កេតលើកាលវិភាគសវនាការ[10]។ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ភាគីបានដាក់សេចក្តីសង្កេតរបស់ខ្លួនលើកាលវិភាគមិនទាន់ស្ពាពរសម្រាប់សវនាការ[11]។

---

[5] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54។

[6] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ F54/1។

[7] សារណាតបរបស់សហមេធាវីនាំមុខទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ ឯកសារលេខ F54/2។

[8] សេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទសវនាការក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ ឯកសារលេខ F58។

[9] ដីកាចាត់តាំងចៅក្រមរបាយការណ៍ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១ ឯកសារលេខ F59។

[10] ការអញ្ជើញភាគីដាក់សេចក្តីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១ ឯកសារលេខ F60។

[11] សារណារបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងកាលវិភាគសម្រាប់សវនាការ (សំណុំរឿង ០០២/០២) ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/1។ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/2។ សេចក្តីសង្កេតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកាលវិភាគដែលបានស្នើឡើងសម្រាប់សវនាការបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/3។

នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២១ សហមេធាវីនាំមុខបានឆ្លើយតបទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន[12]។

5. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២១ សហមេធាវីនាំមុខបានដាក់សំណើសុំពន្យារពេល[13]។

6. នៅថ្ងៃដដែល មេធាវីការពារក្តីបានដាក់សារណាតបទៅនឹងសំណើសុំពន្យារពេល ("សេចក្តីសង្កេតរបស់មេធាវីការពារក្តី")[14]។ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងសំណើសុំពន្យារពេលនេះ("សារណាតបរបស់សហព្រះរាជអាជ្ញា")[15]។

7. នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ អង្គជំនុំជម្រះបានជូនដំណឹងជាផ្លូវការដល់ភាគីថា សវនាការត្រូវបានផ្អាកដោយសារស្ថានភាពជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា[16]។

8. នៅថ្ងៃដដែល ការិយាល័យរដ្ឋបាលបានដាក់ការឆ្លើយតបរបស់ខ្លួន ដែលមានភ្ជាប់មកជាមួយនូវឯកសារមកពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ចំណាងជើងថា"ពិធីការ និងវិធានការការពារជំងឺកូវីដ-១៩" ឧបសម្ព័ន្ធ គ ("ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល និង"របាយការណ៍ការវាយតម្លៃខាងក្រៅ")[17]។

---

[12] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន លើកាលវិភាគសវនាការបណ្តឹងសាទុក្ខដែលបានស្នើឡើង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/1/1។

[13] សណើសុំពន្យារពេល។

[14] សេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តី បន្ទាប់ពីសំណើសុំលើកពេលសវនាការលើបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F61/1 (ដាក់ជាភាសាបារាំង និងខ្មែរ)។

[15] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលសវនាការលើបណ្តឹងសាទុក្ខ ដែលបានគ្រោងធ្វើនៅថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F61/2 ("សារណាតបរបស់សហព្រះរាជអាជ្ញា")។

[16] ការជូនដំណឹងពាក់ព័ន្ធទៅនឹងសវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F62។

[17] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំផ្អាកសវនាការបណ្តឹងសាទុក្ខ ដែលបានគ្រោងសម្រាប់ថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F61/3។ ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល ឧបសម្ព័ន្ធ គ៖ ពិធីការ និងវិធានការការពារជំងឺកូវីដ-១៩ ឯកសារលេខ F61/3.4។

9. នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២១ អង្គជំនុំជម្រះបានចេញដីកាបង្គាប់ឱ្យបុគ្គលិកផ្នែកប្រព័ន្ធព័ត៌មានវិទ្យា (ICT) នៃ អ.វ.ត.ក. ចូលក្នុងមន្ទីរឃុំឃាំង ខៀវ សំផន ដំឡើងឧបករណ៍សោតទស្សន៍ដើម្បីអាចឱ្យគាត់ទំនាក់ទំនងជាមួយសហមេធាវីរបស់គាត់[18]។

10. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសង្កេតរបស់ខ្លួន និងសំណើផ្អែកលើការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល ("សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា")[19]។

11. នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១ ផ្នែកគ្រប់គ្រងតុលាការ (CMS) បានជូនដំណឹងអង្គជំនុំជម្រះអំពីការត្រៀមលក្ខណៈរួចរាល់ក្នុងការជួយសម្រួលដល់សវនាការ ដោយអនុវត្តតាមវិធានការការពារជំងឺកូវីដ-១៩ ដោយបានពន្យល់ថា (i) ទទួលបានវិធានការការពារជំងឺកូវីដ-១៩ ដែលបានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍ការវាយតម្លៃខាងក្រៅ (ទឹកអាល់កុលលាងដៃ ម៉ាស់ របាំងមុខ ទឹកបាញ់សម្លាប់មេរោគ ស្រោមដៃ និងប្រដាប់វាស់កម្តៅ) និងណែនាំមន្ត្រីសន្តិសុខអំពីពិធីការដើម្បីកាត់បន្ថយហានិភ័យជំងឺកូវីដ-១៩ (ii) បានធ្វើការកែសម្រួលបន្ទប់សវនាការជារូបវន្តតាមអនុសាសន៍អ្នកជំនាញ (iii) បានសាកល្បងដោយជោគជ័យនូវប្រព័ន្ធសោតទស្សន៍ទំនាក់ទំនងពីបន្ទប់សវនាការ "ក្រោមលក្ខខណ្ឌ'សវនាការ'សាកល្បងដែលរួមមានអ្នកចូលរួម និងអ្នកបកប្រែផ្ទាល់ និងពីចម្ងាយជាភាសាខ្មែរ បារាំង និងអង់គ្លេស"("ការជូនដំណឹងរបស់ CMS ស្តីពីការត្រៀមលក្ខណៈរួចរាល់")[20]។

---

[18] ដីកាបង្គាប់មន្ទីឃុំឃាំងអនុញ្ញាតឱ្យបុគ្គលិកផ្នែក ICT របស់ UNARKT/ECCC ចូលក្នុងមន្ទីឃុំឃាំងដើម្បីដំឡើងឧបករណ៍ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២១ ឯកសារលេខ F63។

[19] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា និងសំណើផ្អែកលើការឆ្លើយតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលសវនាការបណ្តឹងសាទុក្ខដែលបានគ្រោងសម្រាប់ថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ ឯកសារលេខ F61/3/1។

[20] សេចក្តីជូនដំណឹងរបស់ CMS អំពីលក្ខណៈរួចរាល់សម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២១ (ដាក់នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១) ឯកសារលេខ F64.1 កថាខណ្ឌ ២ ដល់ ៤។

12. នៅថ្ងៃទី ១៧ និង ២០ ខែ ឧសភា ឆ្នាំ ២០២១ មេធាវីការពារក្តី និងសហមេធាវីនាំមុខបានដាក់សេចក្តីសង្កេតរៀងៗខ្លួនស្តីពីទម្រង់បែបបទនៃសវនាការ ("សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ" និង"សេចក្តីសង្កេតរបស់សហមេធាវីនាំមុខលើទម្រង់បែបបទ")[21]។

13. នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២១ ចៅក្រមប្រាំមួយរូបក្នុងចំណោមប្រាំពីររូបនៃអង្គជំនុំជម្រះ និងមន្ត្រីច្បាប់ បានអញ្ជើញទៅពិនិត្យបន្ទប់សវនាការជាមួយលោកអនុប្រធានការិយាល័យរដ្ឋបាល និងជាអ្នកសម្របសម្រួលអង្គការសហប្រជាជាតិសម្រាប់គាំទ្រការកាត់ក្តីខ្មែរក្រហម ដើម្បីបង្កើតវិធានការអនុវត្ត។

## **សារណា**

### *សារណាស្តីពីការពន្យារពេលសវនាការ*

#### *(i) សហមេធាវីនាំមុខ*

14. សហមេធាវីនាំមុខស្នើសុំថា ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ សវនាការដែលគ្រោងធ្វើនៅថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ គប្បីត្រូវពន្យារពេលយ៉ាងតិចណាស់ពីរខែត្រឹមខែ កក្កដា ឆ្នាំ ២០២១[22]។ សហមេធាវីនាំមុខលើកឡើងថា ការពន្យារពេលបានផ្តល់ ឬបង្កើតឱកាសចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការ ការចូលរួមដោយផ្ទាល់ប្រកបដោយសុវត្ថិភាព និងទទួលខុសត្រូវនៅក្នុងបន្ទប់សវនាការ ការត្រៀមរៀបចំគ្រប់គ្រាន់ត្រូវធ្វើឡើងសម្រាប់សវនាការក្នុងលក្ខណៈចម្រុះ ឬតាមប្រព័ន្ធអ៊ីនធឺណិតទាំងស្រុងក្នុងករណីដែលចាំបាច់[23]។ សហមេធាវីនាំមុខលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានអត្ថប្រយោជន៍ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខដែលត្រឹមត្រូវ ឆាប់រហ័ស និងតម្លាភាព ក្នុងនាមជាភាគីនៃរឿងក្តីនេះ សហមេធាវីនាំមុខទទួលអត្ថប្រយោជន៍ នៅពេលអាចចូលរួមការដេញដោលចុងក្រោយក្នុងរឿងក្តី ដរាបណាមានមធ្យោបាយធានាសុវត្ថិភាពចូលរួម[24]។ ការពន្យារពេលត្រូវបានតម្រូវដោយសារកត្តា

---

[21] សេចក្តីសង្កេតពីមេធាវីការពារក្តីលើនីតិវិធីនៃវនាការបណ្តឹងសាទុក្ខ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១ ដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២១។ សេចក្តីសង្កេតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើទម្រង់បែបបទនៃសវនាការ និងការឆ្លើយតបទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១ ឯកសារលេខ F64/2។

[22] សំណើសុំពន្យារពេល កថាខណ្ឌ ១៣, ២២, ៣៧, ៥៣, ៦១, ៧២ (i)។

[23] សំណើសុំពន្យារពេល កថាខណ្ឌ ២២។

[24] សំណើសុំពន្យារពេល កថាខណ្ឌ ២២, ២៩-៣០, ៦៦, ៧០, ៧២ (iv)។

មួយចំនួនដូចជា៖ (i) សវនាការដែលមានសមាសភាពចូលរួមផ្ទាល់ អាចសម្រេចគោលដៅនៃសវនាការបានយ៉ាងល្អប្រសើរ[25] (ii) ស្ថានភាពជំងឺកូវីដ-១៩ ក្នុងប្រទេសកម្ពុជា[26] (iii) ហានិភ័យខ្ពស់ពាក់ព័ន្ធទៅនឹងការចូលរួមផ្ទាល់(រួមបញ្ចូលទាំងការបិទខ្ទប់“តំបន់ក្រហម” និងការរឹតត្បិតការធ្វើដំណើរ)[27] និង(iv) កម្រិតនៃការរៀបចំសម្រាប់សមាសភាពនៃការចូលរួមពីចម្ងាយ“ស្ទើរតែទាំងស្រុង”[28]។

*(ii) មេធាវីការពារក្តី*

15. មេធាវីការពារក្តីស្នើឡើងថា អង្គជំនុំជម្រះគប្បីសម្រេចបន្ទាន់ បើទោះបីក្រៅផ្លូវការ ទៅលើសំណើសុំពន្យារពេល ត្រឹមថ្ងៃទី ២៨ ខែ មេសា ដើម្បីកាត់បន្ថយចំណាយមិនចាំបាច់ ដោយសារសហមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន ត្រូវគ្រោងធ្វើដំណើរមករាជធានីភ្នំពេញនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២១[29]។ មេធាវីការពារក្តីពន្យល់ថា មានការលំបាកក្នុងការពិគ្រោះជាមួយ ខៀវ សំផន ដោយសារការរឹតត្បិតការធ្វើដំណើររបស់រាជរដ្ឋាភិបាលក្នុងស្ថានភាពជំងឺកូវីដ-១៩ ក្នុងរាជធានីភ្នំពេញ និងថា សំណើបន្ទាន់របស់ខ្លួនសុំដំឡើងមធ្យោបាយទំនាក់ទំនងជាមួយ ខៀវ សំផន នៅពុំទាន់បានសម្រេចនៅឡើយ[30]។ នៅពេលពន្យល់ថា ខ្លួនពុំអាចឆ្លើយតបទៅនឹងសំណើសុំពន្យារពេលបានដោយសារពុំមានការពិគ្រោះជាមួយ ខៀវ សំផន មេធាវីការពារក្តីបានទទួលស្គាល់នូវសារៈសំខាន់នៃសំណួរដែលបានលើកឡើងដោយសហមេធាវីនាំមុខ[31]។

16. មេធាវីការពារក្តីបញ្ជាក់បន្ថែមទៀតថា សហមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន ពុំអាចធ្វើដំណើរមករាជធានីភ្នំពេញបានក្នុងអំឡុងនៃការពន្យារពេលក្នុងខែ មិថុនា ឬកក្កដា ឆ្នាំ ២០២១ ប៉ុន្តែបញ្ជាក់ពីអត្ថិភាពរបស់ខ្លួនក្នុងខែ សីហា[32]។ ការធ្វើដំណើរមករាជធានីភ្នំពេញសម្រាប់កាលបរិច្ឆេទក្នុងខែ សីហា

---

[25] សំណើសុំពន្យារពេល កថាខណ្ឌ ២៣-៣៦, ៦៨។

[26] សំណើសុំពន្យារពេល កថាខណ្ឌ ៣៨-៤២។

[27] សំណើសុំពន្យារពេល កថាខណ្ឌ ៤៣-៥៣។

[28] សំណើសុំពន្យារពេល កថាខណ្ឌ ៥៤-៦៥, ៦៧។

[29] សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ៦។

[30] សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ៧។

[31] សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ៨។

[32] សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ៩។

នឹងត្រូវចំណាយពេលពីរសប្តាហ៍ធ្វើចន្លាឡឺស័កមុនពេលចូលរួមសវនាការ និងពីរសប្តាហ៍ទៀតក្រោយពេលទៅដល់អឺរ៉ុបវិញ។ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះធ្វើកាលវិភាគចុងក្រោយ និងសំណួររបស់ចៅក្រមដល់ភាគីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[33]។

*(iii) សហព្រះរាជអាជ្ញា*

17. សហព្រះរាជអាជ្ញាបានឆ្លើយតបថា កាលបរិច្ឆេទសវនាការ គឺស្ថិតក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ[34] និងបានស្នើសុំអង្គជំនុំជម្រះសម្រេចឱ្យបានឆាប់រហ័សលើសំណើសុំពន្យារពេល និងជូនដំណឹងភាគីទោះបីផ្លូវការ ឬក្រៅផ្លូវការ[35]។

## *សារណាស្តីពីទម្រង់បែបបទនៃសវនាការ*

*(i) សហមេធាវីនាំមុខ*

18. សហមេធាវីនាំមុខបានស្នើសុំឱ្យការិយាល័យរដ្ឋបាលចាត់វិធានការចាំបាច់ជួយសម្រួលវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ ដោយចាត់ទុកឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាភាគីនៃកិច្ចដំណើរការនីតិវិធី[36]។ ទាក់ទងទៅនឹងការត្រៀមរៀបចំសវនាការ សហមេធាវីនាំមុខបានស្នើសុំថា៖ (i) ការចេញសេចក្តីណែនាំបំភ្លឺដល់អ្នកចូលរួមឱ្យបានយល់ច្បាស់ជាមួយនីតិវិធីដែលបានប្រើប្រាស់ ព្រមទាំងការធ្វើតេស្តសាកល្បង[37] (ii) ការិយាល័យរដ្ឋបាលត្រូវលើកសំណើជាក់លាក់មកឱ្យភាគីដើម្បីផ្តល់ជាគំនិត និងកត់សម្គាល់ថា បញ្ហាជាក់លាក់ជាច្រើនដែលភាគីនៅពុំទាន់យល់ដឹងដូចជា៖

> [...] ការចូលរួមពីចម្ងាយតម្រូវឱ្យមានឧបករណ៍ផ្សេងៗ ដូចជា ថាមពល និងប្រព័ន្ធអ៊ីនធឺណិត អត្ថិភាពនៃប្រតិចារឹកផ្ទាល់ មធ្យោបាយសម្រាប់ការទំនាក់ទំនងជាមួយសមាជិកក្រុម អត្ថិភាពនៃការគាំទ្រផ្នែកប្រព័ន្ធព័ត៌មានវិទ្យាដល់ភាគីទាំងអស់ លទ្ធភាពសម្រាប់ចៅក្រម និងមេធាវីអាចមើលឃើញគ្នាទៅវិញទៅមកក្នុងអំឡុងពេលពិភាក្សា ការតាមដានរបស់ ខៀវ សំផន តម្រូវការសម្រាប់ការផ្សាយមិនផ្ទាល់ទៅសាធារណៈ ព្រមទាំង

---

[33] សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ១០-១១។

[34] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[35] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

[36] សំណើសុំពន្យារពេល កថាខណ្ឌ ២៨-៣០, ៣៤, ៧១, ៧២ (iv)។

[37] សំណើសុំពន្យារពេល កថាខណ្ឌ ៦៣។

ការផ្សាយបន្តផ្ទាល់ពីអ្នកចូលរួមពីចម្ងាយ ផែនការសម្រាប់ការសាកល្បង និងការសាកល្បងប្រើប្រាស់កម្មវិធីកុំព្យូទ័រប្រព័ន្ធបច្ចេកវិទ្យាថ្មី និងការចេញវិធាន និងសេចក្តីណែនាំសម្រាប់ការធ្វើសវនាការ [...][38]

19. សហមេធាវីនាំមុខបានលើកឡើងថា តាមរបាយការណ៍វាយតម្លៃខាងក្រៅ គឺពុំអាចគ្រប់គ្រាន់"ធ្វើឱ្យការសង្កេតរបស់ភាគី ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមួយមានអត្ថន័យពេញលេញនោះទេ"[39]។ តាមគំនិតរបស់ខ្លួន របាយការណ៍ការវាយតម្លៃខាងក្រៅពុំអាច"ឈានដល់ការផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការសម្រេចលើទម្រង់បែបបទ នៃការចូលរួមសវនាការដោយផ្ទាល់" ដោយសារមានកង្វះនូវជំនាញគ្រប់គ្រាន់ ហេតុផលវិទ្យាសាស្ត្រ យុត្តិកម្ម និងភាពច្បាស់លាស់ពាក់ព័ន្ធទៅនឹងអនុសាសន៍មួយចំនួន[40]។ សហមេធាវីនាំមុខព្រួយបារម្ភជាពិសេសថា៖ (i) របាយការណ៍វាយតម្លៃខាងក្រៅ ទំនងជាពុំបានពិចារណាលើហានិភ័យជំងឺឆ្លងតាមខ្យល់[41] (ii) ការលើកសំណើនៃ"របាំងពពុះ" គឺ"គ្មានតម្លៃជាក់ស្តែង"[42] និង (iii) វិធានការជាក់ស្តែងជាសក្តានុពលដូចជាការធ្វើតេស្តភ្លាមៗ និងស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់អ្នកចូលរួម ពុំត្រូវបានលើកយកមកពិចារណា[43]។

20. សហមេធាវីនាំមុខបានលើកឡើងថា អង្គជំនុំជម្រះគប្បីចាត់តាំងអ្នកជំនាញឯកទេសខាងការការពារ និងគ្រប់គ្រងជំងឺឆ្លង ដោយអនុលោមតាមវិធាន ៣១ នៃវិធានផ្ទៃក្នុង ដើម្បីផ្តល់អនុសាសន៍មានសំអាងហេតុត្រឹមត្រូវលើ៖ (i) វិធានការកាត់បន្ថយហានិភ័យការឆ្លងតាមខ្យល់ (ii) ផលប៉ះពាល់នៃការចាក់ថ្នាំបង្ការអ្នកចូលរួម (iii) ការធ្វើតេស្តភ្លាមៗ និង (iv) ជម្រើសសម្រាប់ការចូលរួមផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដោយសុវត្ថិភាព ឬតាមដានពីចម្ងាយ[44]។ សហមេធាវីនាំមុខបានបង្ហាញនូវនត្ថិភាពនៃអនុសាសន៍ពាក់ព័ន្ធទៅនឹងវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាំងនៅក្នុងការវាយតម្លៃពីខាងក្រៅ ឬនៅក្នុងសេចក្តីជូនដំណឹងអំពីភាពរួចរាល់របស់ CMS (ទោះជាយ៉ាងណាក្តី រូបភាពនៃការកែសម្រួលបន្ទប់សវនា

[38] សំណើសុំពន្យារពេល កថាខណ្ឌ ៥៧-៥៨, ៦២, ៧០, ៧២(v)។

[39] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ២។

[40] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ២០-២៥, ២៧, ៣៩-៤០។

[41] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ២៨-៣៣។

[42] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៣៥-៣៦។

[43] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៣៧។

[44] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ២-៣, ២៦, ៤១, ៦៨ (i)។

ការបានបង្ហាញថា កន្លែងអង្គុយដែលជាធម្មតាទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដកចេញ)[45]។ សហមេធាវីនាំមុខបានទទួចសុំគំនិតរបស់អ្នកជំនាញ“ដើម្បីផ្តល់លទ្ធភាព ដែលអាចអនុវត្តបានលើវិធានការក្នុងការធានាវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយសុវត្ថិភាព” ព្រមទាំងជម្រើសនៃការចូលរួមនៅទីកន្លែងខាងក្រៅដែលមានដំបូល[46]។

21. ប្រសិនបើពុំមានអនុសាសន៍ណែនាំបន្ថែមរបស់អ្នកជំនាញ សហមេធាវីនាំមុខលើកឡើងថា ខ្លួនពុំអាចលើកសារណាស្តីពីការចូលរួមប្រកបដោយសុវត្ថិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ[47]។ បន្ថែមលើនេះ សហមេធាវីនាំមុខយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ក្រុមការងារគប្បីអាចប្តូរវេនគ្នាធ្វើបទបង្ហាញនៅក្នុងបន្ទប់សវនាការ និងអះអាងថា សមាជិកក្រុមនឹងត្រូវទំនាក់ទំនងគ្នាក្រៅសវនាការនៅគ្រប់ករណី[48]។ សហមេធាវីនាំមុខបានសង្កេតផងដែរថា ទីកន្លែងគប្បីត្រូវបានបែងចែកសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងតំបន់ដើមបណ្តឹងរដ្ឋប្បវេណី និងថា បុគ្គលទាំងឡាយដែលវត្តមានរបស់ខ្លួនពុំរួមចំណែកផ្ទាល់ដល់កិច្ចដំណើរការនីតិវិធី គប្បីត្រូវបានកម្រិត ដើម្បីអនុញ្ញាតឱ្យក្រុមអ្នកច្បាប់មានសមាជិកច្រើនតាមអាចធ្វើទៅបានមានវត្តមានក្នុងតំបន់ដែលបានផ្តល់អនុសាសន៍ ហើយអង្គជំនុំជម្រះគប្បីផ្តល់សេចក្តីណែនាំច្បាស់លាស់ពីបញ្ហា ថាតើមានអ្នកចូលរួមប៉ុន្មាននាក់ដែលមិនធ្វើសកម្មភាព (ដូចជាសន្តិសុខ និងមន្ត្រីសុខាភិបាល) ត្រូវបានអនុញ្ញាតឱ្យមានវត្តមាន[49]។

22. បើទោះបីជាមានទំនោរចិត្តខ្លាំងទៅរកការចូលរួមសវនាការដោយផ្ទាល់ក៏ដោយ ក៏សហមេធាវីនាំមុខចាត់ទុកថា ជាការសំខាន់ដែលត្រូវមានការរៀបចំគ្រប់គ្រាន់ពេញលេញសម្រាប់ការចូលរួមពីចម្ងាយ[50]។ សហមេធាវីនាំមុខបានអះអាងម្តងទៀតថា អង្គជំនុំជម្រះគប្បីបង្គាប់ការិយាល័យរដ្ឋបាលស្នើឡើងនូវគំនិតនៃទម្រង់បែបបទនៅក្នុងកាលបរិច្ឆេទជាក់លាក់មួយសម្រាប់ការចូលរួមសវនាការពីចម្ងាយ ដោយដោះស្រាយបញ្ហាមួយចំនួនដែលពុំទាន់បានឆ្លើយតប និងផ្តល់ឱ្យភាគីនូវឱកាសក្នុងការឆ្លើយតបប្រកបដោយ

---

[45] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ១៩។

[46] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៤២។

[47] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៤៤។

[48] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៤៥-៤៦។

[49] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៤៧-៤៩។

[50] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៣, ២៦, ៥០។ *សូមមើលផងដែរ* កថាខណ្ឌ ៦៣-៦៥។

អត្ថន័យទៅនឹងការស្នើនោះ[51]។ សហមេធាវីនាំមុខបានបង្ហាញថា បញ្ហាខាងក្រោមនៅពុំទាន់ដោះស្រាយនៅឡើយដូចជា៖ (i) ការផ្តល់សម្ភារៈដល់ក្រុមការងាររបស់សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ii) ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតអាចទុកចិត្តបាន អគ្គីសនី និងទីតាំងឯកជនសម្រាប់ការចូលរួមសវនាការ (iii) មធ្យោបាយសម្រាប់ក្រុមការងារពិភាក្សាជាមួយគ្នាក្នុងអំឡុងពេលសវនាការ (iv) ការផ្សាយបន្តផ្ទាល់ និងមិនផ្ទាល់ដាច់ដោយឡែកសម្រាប់ក្រុមការងារពីចម្ងាយ (v) ប្រតិចារឹកផ្ទាល់ (vi) ការចូលរួមបានត្រឹមត្រូវសម្រាប់អ្នកចូលរួមពីចម្ងាយ (vii) ការដឹងពេលវេលាសម្រាប់សាកល្បងការចូលរួមពីចំងាយយ៉ាងតិចដប់ប្រាំថ្ងៃមុនពេលសវនាការ និងបានកត់សម្គាល់ថា ទាំងអស់នេះពុំទាន់ត្រូវបានដោះស្រាយតាមរយៈការដំឡើង"វីដេអូសាកល្បងធ្វើត្រាប់សវនាការ"ដោយការិយាល័យរដ្ឋបាល (viii) ការចេញសេចក្តីណែនាំ ឬពិធីការសម្រាប់សវនាការ និង (ix) ពាក្យស្លោកណែនាំ ឬវិធានការផ្សេងៗសម្រាប់ឱ្យសាធារណៈជនយល់ដឹង[52]។ សហមេធាវីនាំមុខបានបន្ថែមថា អង្គជំនុំជម្រះត្រូវគ្រប់គ្រងមីក្រូហ្វូនរបស់អ្នកចូលរួមពីចម្ងាយក្នុងអំឡុងពេលសវនាការ និងបម្រុងពេលវេលាបន្ថែមសម្រាប់បញ្ហាបច្ចេកទេសកើតឡើង[53]។

23. សហមេធាវីនាំមុខបានសម្តែងក្តីបារម្ភអំពី"ការបង្ហាញនូវជំនឿ"របស់ការិយាល័យរដ្ឋបាលចំពោះការរៀបចំបានគ្រប់គ្រាន់ និងទាន់ពេល[54]។ សហមេធាវីនាំមុខបានសង្កត់ធ្ងន់ថា ត្រូវតែមានការហ្វឹកហាត់ប្រព័ន្ធកម្មវិធីកុំព្យូទ័រគ្រប់គ្រាន់ នៅពេលណាដែលឧបករណ៍ចាំបាច់ និងទីកន្លែងនៃការិយាល័យត្រូវបានផ្តល់ឱ្យបានមុនពេលធ្វើតេស្តសាកល្បងប្រព័ន្ធ[55]។ សហមេធាវីបានលើកក្តីបារម្ភពាក់ព័ន្ធទៅនឹងការសាកល្បងធ្វើត្រាប់សវនាការរបស់ CMS ដោយពុំមានការចូលរួមពីភាគី និងមានតែវីដេអូបង្ហាញពីដំណើរការដែលបានចែករំលែកប៉ុន្មានអាទិត្យក្រោយមកប៉ុណ្ណោះ[56]។

---

[51] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ២, ៤, ១៥, ២៦, ៦៨ (ii)។

[52] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពី ទម្រង់បែបបទ កថាខណ្ឌ ៥៥ (i)-(ix)។

[53] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពី ទម្រង់បែបបទ កថាខណ្ឌ ៥៦។

[54] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៥៧។

[55] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៥៨-៥៩។

[56] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៦០។

24. ដោយយល់ស្របជាមួយនឹងភាគីដទៃទៀតដែលលើកឡើងថា កាលបរិច្ឆេទសវនាការគប្បីត្រូវបានកំណត់ឱ្យបានឆាប់តាមអាចធ្វើទៅបាន សហមេធាវីនាំមុខស្នើជាគំនិតថា អង្គជំនុំជម្រះគប្បីផ្តល់"ការបង្ហាញពេលវេលាប្រហាក់ប្រហែល ឬកាលបរិច្ឆេទ'ដែលមិនធ្វើមុនពេលណាមួយ'"[57] និងបានស្នើសុំថាសំណើសុំរបស់អង្គជំនុំជម្រះគប្បីផ្តល់ឱ្យភាគីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប្រសិនបើមាន[58]។

25. ចំពោះការស្នើឡើងរបស់ការិយាល័យរដ្ឋបាលឱ្យដាក់សវនាការជាលាយលក្ខណ៍អក្សរជំនួសសវនាការផ្ទាល់មាត់ សហមេធាវីនាំមុខបានលើកឡើងថា ការិយាល័យរដ្ឋបាលទំនងជាសន្មតពុំត្រឹមត្រូវថា អាចជួយកាត់បន្ថយពេលវេលា និងចំណាយបាន[59]។ សហមេធាវីនាំមុខបានបន្ថែមថា សារណាជាលាយលក្ខណ៍អក្សរលើ"បញ្ហាខុសៗគ្នា" អាចត្រូវបំពេញបន្ថែមដោយសវនាការខ្លីៗ[60]។

*(ii) ការិយាល័យរដ្ឋបាល*

26. ការិយាល័យរដ្ឋបាលបានសង្កេតឃើញថា ប្រសិនបើអង្គជំនុំជម្រះពិចារណាឃើញថា សវនាការពុំអាចធ្វើបានក្នុងខែ ឧសភា សារណាជាលាយលក្ខណ៍អក្សរអាចជំនួសសារណាផ្ទាល់មាត់"ដើម្បីរក្សាការព្យាករណ៍នៃរឿងក្តីបច្ចុប្បន្ន និងការរំពឹងទុករបស់សាធារណជន"[61]។

27. ការិយាល័យរដ្ឋបាលដើរតាមជំហានបន្តបន្ទាប់របស់ខ្លួនរហូតមកដល់បច្ចុប្បន្ន និងបានជូនដំណឹងអង្គជំនុំជម្រះថា ការិយាល័យរដ្ឋបាលនឹងត្រៀមរៀបចំសម្រាប់ទម្រង់បែបបទនៃសវនាការណាមួយ[62]។ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២១ ការិយាល័យរដ្ឋបាលបានទទួលកម្មវិធីទំនាក់ទំនងតាមប្រព័ន្ធសោតទស្សន៍ជួយសម្រួលដល់ការចូលរួមពីចម្ងាយនៅពេលសវនាការ ដែលបុគ្គលិកនៃផ្នែក ICT និង CMS កំពុងហ្វឹកហាត់ប្រើប្រាស់ប្រព័ន្ធនេះ[63]។ ការិយាល័យរដ្ឋបាលបានទាក់ទងអ្នកចុះកិច្ចសន្យាខាងក្រៅដើម្បីអនុវត្ត

---

[57] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៦៦, ៦៨ (iii)។

[58] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៦៧-៦៨ (iv)។

[59] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៥, ៦២។

[60] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៥, ៦២។

[61] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៤។

[62] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៥។

[63] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៧។

វិធានការកាត់បន្ថយហានិភ័យជំងឺកូវីដ-១៩ក្នុងបន្ទប់សវនាការ[64]។ ការិយាល័យរដ្ឋបាលបានអញ្ជើញមន្ត្រីទំនាក់ទំនងវេជ្ជសាស្ត្រផ្នែកជំងឺកូវីដ-១៩ របស់អង្គការសហប្រជាជាតិមកទស្សនាបន្ទប់សវនាការ និងជាលទ្ធផលបានធ្វើរបាយការណ៍ការវាយតម្លៃខាងក្រៅ រៀបរាប់ពីអនុសាសន៍ការពារជំងឺកូវីដ-១៩ ត្រូវអនុវត្តក្នុងបន្ទប់សវនាការ និងតាមច្រកចូលបរិវេណ អ.វ.ត.ក.[65]។ ការិយាល័យរដ្ឋបាលអះអាងថា ខ្លួននឹង (i) ធ្វើការកែសម្រួលផ្ទាល់តាមអនុសាសន៍ក្នុងបន្ទប់សវនាការ (ii) ដំឡើងប្រព័ន្ធ IT "ឱ្យបានមុនពេលកាលបរិច្ឆេទសវនាការ"[66] (iii) បែងចែកធនធាន IT និង"ពន្លាតការគាំទ្រផ្នែកបច្ចេកទេសចាំបាច់"ដល់អ្នកចូលរួមពីចម្ងាយ និង(iv) ផ្តល់ការហ្វឹកហាត់កម្មវិធីកុំព្យូទ័រផ្នែក software "មួយសប្តាហ៍មុនពេលសវនាការ"[67]។ ការិយាល័យរដ្ឋបាលសន្និដ្ឋានថា ខ្លួនបានចែករំលែករបាយការណ៍វាយតម្លៃខាងក្រៅជាមួយនឹងភាគី និងថា "វត្តមានរបស់ភាគីទាំងអស់(រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី) [...] អាចត្រូវបានជួយសម្រួលផ្អែកតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការរៀបចំសវនាការ"[68]។

*(iii) សហព្រះរាជអាជ្ញា*

28. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា បញ្ហាដែលបានលើកឡើងក្នុងសំណើសុំផ្អាកសវនាការត្រូវតែត្រូវបានដោះស្រាយនៅមុនពេលសវនាការ[69]។ សហព្រះរាជអាជ្ញាយល់ស្របជាមួយនឹងសហមេធាវីនាំមុខលើសារៈសំខាន់នៃចំណុចមួយចំនួននៃការចូលរួមផ្ទាល់របស់ភាគី ជាផលប្រយោជន៍សម្រាប់"សាធារណជនយល់ដឹងពីតុលាការ និងការតាមដានកិច្ចដំណើរការនីតិវិធី"[70]។

29. ជាការឆ្លើយតបទៅនឹងការិយាល័យរដ្ឋបាល សហព្រះរាជអាជ្ញាសង្កេតឃើញថា អនុសាសន៍នៃរបាយការណ៍វាយតម្លៃខាងក្រៅ"ពុំស្របគ្នាជាមួយនឹងអ្វីដែលខ្លួនបានកំណត់ថា អាចត្រៀម និងធ្វើបទ

[64] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៧។

[65] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៧ យោងទៅលើរបាយការណ៍វាយតម្លៃខាងក្រៅ។

[66] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៨-៩។

[67] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៩។

[68] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១០។

[69] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[70] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

បង្ហាញសារណាផ្ទាល់មាត់ឱ្យបានល្អបំផុតនោះឡើយ”[71]។ ទីមួយ ទាក់ទងទៅនឹងការកម្រិតចំនួនបុគ្គលិករបស់អយ្យការចូលរួមផ្ទាល់ត្រឹមបួននាក់ ដែលអ្នកធ្វើបទបង្ហាញពីរនាក់សម្រាប់សវនាការទាំងមូល សហព្រះរាជអាជ្ញាស្នើឡើងថា ត្រូវអនុញ្ញាតប្រាំមួយនាក់ចូលក្នុងបន្ទប់សវនាការគ្រប់ពេល[72]។ ទីពីរ ទាក់ទងទៅនឹងលក្ខខណ្ឌនៃ“របាំងពពុះ” ដែលត្រូវមានបុគ្គលិកបួននាក់វត្តមានក្នុងបន្ទប់សវនាការសម្រាប់អំឡុងពេលនៃសវនាការ សហព្រះរាជអាជ្ញាស្នើសុំលទ្ធភាពប្តូរវេនគ្នាទាំងប្រាំមួយនាក់របស់អយ្យការរវាងវគ្គនីមួយៗ និងកត់សម្គាល់ថា ទោះជាយ៉ាងណាក្តី ពុំមាន“របាំងពពុះ”ត្រូវបានបង្កើតឡើង ដោយសារអ្នកទាំងនោះដែលមានវត្តមានក្នុងបន្ទប់សវនាការ នឹងត្រូវត្រឡប់ទៅផ្ទះរបស់ខ្លួន និងមកបន្ទប់សវនាការវិញជារៀងរាល់ថ្ងៃ[73]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការដំឡើងរបាំងកញ្ចក់ខ្ពស់បីម៉ែត្រដាច់ពីគ្នាទាំងប្រាំមួយនាក់ផ្តល់ការការពារគ្រប់គ្រាន់ និងបានបញ្ជាក់ថា អ្នកទាំងប្រាំមួយនាក់នោះបានចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ លើកទីមួយ និងត្រូវចាក់លើកទីពីរនៅចុងខែឧសភា[74]។ ទីបី សហព្រះរាជអាជ្ញាស្នើសុំថា អ្នកធ្វើបទបង្ហាញពុំតម្រូវឱ្យពាក់របាំងមុខដែលពុំចាំបាច់ដោយសារមានការការពារគ្រប់គ្រាន់ និងអាចប៉ះពាល់ដល់ការបកប្រែ និងការទំនាក់ទំនងរវាងភាគី និងចៅក្រម ហើយក៏ជាការពុំត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិនៅតុលាការដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះដែលជំនុំជម្រះក្នុងឆ្នាំ ២០២១ ក្នុងបណ្តាប្រទេសដែលទទួលរងការប៉ះពាល់ដោយជំងឺឆ្លង[75]។

30. សហព្រះរាជអាជ្ញាស្នើសុំថា ត្រូវមានការធ្វើតេស្តសាកល្បងពេញលេញលើឧបករណ៍ និងទម្រង់បែបបទយ៉ាងហោចណាស់ ១៥ ថ្ងៃម្តង មុនពេលសវនាការ និងថា ការអនុញ្ញាតដែលចាំបាច់ពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើដំណើរមករៀបចំ និងចូលរួមសវនាការផ្ទាល់ ត្រូវទទួលបានជាមុន[76]។

31. សហព្រះរាជអាជ្ញាបដិសេធសេចក្តីសន្និដ្ឋានការិយាល័យរដ្ឋបាលដែលលើកឡើងថា “សារណាផ្ទាល់មាត់អាចត្រូវបានជំនួសដោយការលាយលក្ខណ៍អក្សរ ដើម្បីរក្សាការព្យាករណ៍រឿងក្តីបច្ចុប្បន្ន និងការ

[71] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២, ៤។

[72] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤-៥។

[73] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤, ៦-៧, ១៤(១)(២)។

[74] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

[75] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤, ៨-១០, ១៤(៣)។

[76] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១-១២, ១៤(៤)(៥)។

រំពឹងទុករបស់សាធារណជន” និងការពន្យារពេលសវនាការតម្រូវឱ្យមាន“ការចំណាយធនធានផ្នែកហិរញ្ញវត្ថុបន្ថែម”[77]។ តាមគំនិតរបស់សហព្រះរាជអាជ្ញាមានន័យថា ការផ្អាកសវនាការពុំបានបង្កើនការចំណាយបន្ថែម ដោយសារសវនាការតម្រូវឱ្យមានតែធនធានដដែល ដោយពុំជាប់ពាក់ព័ន្ធការធ្វើពេលណានោះទេ និងពុំបានកែប្រែការព្យាករណ៍រឿងក្ដី ដរាបណាកិច្ចការលើសាលដីកាបណ្ដឹងសាទុក្ខនៅតែបន្ត[78]។ សហព្រះរាជអាជ្ញាបន្ថែមថា ការផ្អាកមួយពុំមែនប៉ះពាល់ដល់ការរំពឹងទុករបស់សាធារណជននោះទេ ដោយសារកិច្ចដំណើរការនីតិវិធីជាទូទៅមានរយៈពេលវែង និងការយល់ដឹងរបស់សាធារណជនអំពីបញ្ហាប្រឈមកើតឡើង ដោយសារជំងឺរាតត្បាត[79]។ ផ្ទុយទៅវិញ ការពន្យារពេលនេះពុំបានបង្កើនការងារច្រើន ឬយូរជាងសារណាជាលាយលក្ខណ៍អក្សរ។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា ការធ្វើសារណាជាលាយលក្ខណ៍អក្សរត្រូវការបុគ្គលិកបន្ថែមខាងមេធាវីការពារក្ដី និងការបកប្រែ[80]។

*(iv) មេធាវីការពារក្ដី*

32. មេធាវីការពារក្ដីលើកឡើងថា វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំបានចែងអំពីលទ្ធភាពនៃការធ្វើសវនាការពីចម្ងាយពេញលេញ[81] និងថា សំណើរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខសុំបង្កើនចំនួនអ្នកចូលរួមក្នុងបន្ទប់សវនាការ និងលទ្ធភាពប្ដូរវេនគ្នា ពុំមានអ្វីប៉ះពាល់ដល់ ខៀវ សំផន ឬវត្តមានរបស់គាត់ក្នុងបន្ទប់សវនាការ។ ផ្ទុយទៅវិញប្រសិនបើវិធានការផ្សេងក្រៅពីអ្វីដែលបានណែនាំក្នុងរបាយការណ៍នៃការវាយតម្លៃខាងក្រៅ ត្រូវបានយកមកអនុវត្ត គប្បីជាចម្បងត្រូវឱ្យ ខៀវ សំផន មានវត្តមានក្នុងបន្ទប់សវនាការ[82]។ ដោយបានសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់ ខៀវ សំផន និងចំណង់ចំណូលចិត្តរបស់គាត់មានវត្តមានក្នុងបន្ទប់សវនាការពេញមួយអំឡុងពេលសវនាការ មេធាវីការពារក្ដីបានស្នើសុំថា អង្គជំនុំជម្រះណែនាំវិធានការចាំបាច់ ដើម្បីអាចឱ្យគាត់មានវត្តមានក្នុងបន្ទប់សវនាការសម្រាប់រយៈពេល

[77] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣, យោងទៅលើការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៤ និងជើងទំព័រ ៣១។

[78] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[79] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[80] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[81] សេចក្ដីសង្កេតរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ៦។

[82] សេចក្ដីសង្កេតរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ១១-១៩។

នោះ ឬយ៉ាងហោចណាស់សម្រាប់ការថ្លែងសម្ដីចុងក្រោយរបស់គាត់[83]។ ក្នុងករណីដែលវេជ្ជបណ្ឌិតរបស់ ខៀវ សំផន (តាមការកត់សម្គាល់របស់មេធាវីការពារក្ដីឃើញថា ពុំត្រូវបានពិគ្រោះពិភាក្សាសម្រាប់ការបង្កើតរបាយការណ៍ការវាយតម្លៃខាងក្រៅ) ផ្ដល់អនុសាសន៍ឱ្យ ខៀវ សំផន មានវត្តមានក្នុងបន្ទប់សវនាការមិនលើសពី ១៥ នាទី ខៀវ សំផន នឹងត្រូវតាមដានសវនាការពីបន្ទប់ខាងក្រោម និងស្នើសុំបម្រុងពេលវេលាសម្រាប់វត្តមានរបស់គាត់ក្នុងបន្ទប់សវនាការដើម្បីថ្លែងសម្ដីចុងក្រោយ[84]។

33. ទាក់ទងទៅនឹងរបាយការណ៍វាយតម្លៃខាងក្រៅស្ដីពីវិធានការបង្ការ មេធាវីការពារក្ដីបានសង្កត់ធ្ងន់ពីសារៈសំខាន់ដែលត្រូវគោរពតាមដោយប្រុងប្រយ័ត្ន ជាពិសេសអ្នកដែលត្រូវទំនាក់ទំនងផ្ទាល់ជាមួយនឹង ខៀវ សំផន[85]។ មេធាវីការពារក្ដី ទោះជាយ៉ាងណាក្ដី បានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា របាំងកញ្ចក់ការពារ អាចឱ្យវាគ្មិនពុំចាំបាច់ពាក់របាំងមុខការពារថែមទៀតឡើយ[86] និងកត់សម្គាល់ឃើញថា កាលបរិច្ឆេទសវនាការត្រូវពិចារណាលើពេលវេលាចាំបាច់សម្រាប់បាញ់ថ្នាំសម្លាប់មេរោគ និងការបើកហើយខ្យល់ចេញចូលក្នុងបន្ទប់សវនាការ[87]។

34. មេធាវីការពារក្ដីលើកវិធានការបីចំណុចបន្ថែមទៀត។ ទីមួយ ការធ្វើតេស្តភ្លាមៗប្រចាំថ្ងៃមុនពេលចូលបន្ទប់សវនាការ ឬយ៉ាងហោចណាស់ ចំពោះអ្នកដែលចូលបន្ទប់សវនាការមុនគេ និងធ្វើតេស្តគ្រប់គ្នាទាំងអស់ដែលមានវត្តមានក្នុងបន្ទប់សវនាការនៅថ្ងៃដែល ខៀវ សំផន ថ្លែងសម្ដីចុងក្រោយ ក្នុងករណីដែលគាត់ត្រូវមានវត្តមានក្នុងបន្ទប់សវនាការតែក្នុងអំឡុងពេលនោះប៉ុណ្ណោះ[88]។ ទីពីរ អ្នករាល់គ្នាដែលមានវត្តមានក្នុងបន្ទប់សវនាការ (ឬយ៉ាងហោចណាស់បុគ្គលដែលងាយរងគ្រោះ រួមទាំង ខៀវ សំផន) ត្រូវពាក់ម៉ាស់ប្រភេទ N95 ហើយត្រូវប្ដូរក្នុងរយៈពេលបួនម៉ោងម្ដង[89]។ ទីបី របាំងពពុះនៃការដឹកជញ្ជូនមកតុលាការតាមផ្នែក ត្រូវរៀបចំសម្រាប់រាល់អ្នកដែលចាំបាច់ត្រូវចូលក្នុងបន្ទប់សវនាការ[90]។

---

[83] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ១៦, ៣១។

[84] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២០។

[85] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២៦។

[86] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២៦។

[87] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២៦។

[88] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២២-២៣។

[89] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២៤។

[90] សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ២៥។

35. មេធាវីការពារក្តីយល់ស្របជាមួយភាគីដទៃទៀតថា ការធ្វើតេស្តឧបករណ៍សាកល្បងដែលរួមបញ្ចូលទាំងអ្នកចូលរួមពីចម្ងាយ គប្បីធ្វើឱ្យបានមួយសប្តាហ៍មុនពេលសវនាការ[91]។ ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទសវនាការ មេធាវីការពារក្តីបង្ហាញថា សហមេធាវីការពារក្តីអន្តរជាតិអាចមានវត្តមានក្នុងបន្ទប់សវនាការ ប្រសិនបើសវនាការគ្រោងនឹងធ្វើនៅក្នុងសប្តាហ៍ចាប់ពីថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ និងអាចចូលរួមពីចម្ងាយប្រសិនបើសវនាការប្រព្រឹត្តទៅក្នុងសប្តាហ៍ដទៃទៀត ក្នុងខែសីហា ប៉ុន្តែបើនៅក្រោយខែសីហា អាចនឹងមាន"ការលំបាកកំណត់ប្រតិទិន"[92]។ នៅគ្រប់ករណី មេធាវីការពារក្តីបានបញ្ជាក់ជាថ្មីថា កាលបរិច្ឆេទសវនាការ និងសំណួររបស់អង្គជំនុំជម្រះត្រូវផ្តល់ឱ្យភាគីបានឆាប់តាមដែលអាចធ្វើទៅបាន[93]។

36. ចុងក្រោយ មេធាវីការពារក្តីជំទាស់ទៅនឹងការលើកឡើងរបស់ការិយាល័យរដ្ឋបាលដែលថា អាចជំនួសដោយសារណាជាលាយលក្ខណ៍អក្សរ[94]។ តាមគំនិតរបស់មេធាវីការពារក្តីបញ្ជាក់ថា (i) ផ្ទុយទៅនឹងលក្ខខណ្ឌតម្រូវនៃសវនាការ[95] (ii) រំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន ត្រូវថ្លែងសម្តីចុងក្រោយចំពោះមុខចៅក្រម និងសាធារណជន[96] និង (iii) តម្រូវឱ្យមានពេលវេលាបន្ថែមច្រើន ដោយសារធនធានមានកម្រិតដែលមេធាវីការពារក្តីត្រូវបានផ្តល់ឱ្យ ដូចនេះបានរារាំងដល់ការបំពេញតាមក្របខ័ណ្ឌពេលវេលា និងការរំពឹងទុករបស់សាធារណជន[97]។

---

[91] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ២៨។

[92] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ២៩។

[93] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៣០។

[94] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៦-៩។

[95] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៦ យោងទៅលើវិធានផ្ទៃក្នុង វិធាន ១០៩(១) និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៨៨-៣៩៥, ៤៣៣-៤៣៤។

[96] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៨។

[97] សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៨-៩។

## ច្បាប់ជាធរមាន

37. ច្បាប់ អ.វ.ត.ក. ចែងថា តុលាការ "ត្រូវធានាថា ការជំនុំជម្រះត្រឹមត្រូវ និងបានឆាប់រហ័ស និងត្រូវអនុលោមតាមនីតិវិធីជាធរមាន ដោយត្រូវគោរពពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងសម្រាប់ការពារជនរងគ្រោះ [...]"[98] និងចែងបន្ថែមទៀតថា ជនជាប់ចោទត្រូវទទួលបានការធានាជាអប្បបរមាដូចខាងក្រោមៈ

ខ. ត្រូវមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

គ. ត្រូវបានទទួលការជំនុំជម្រះដោយគ្មានអូសបន្លាយ

ឃ. ត្រូវបានទទួលការជំនុំជម្រះដោយមានវត្តមានរបស់ជនជាប់ចោទ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ដែលជ្រើសរើសដោយខ្លួនឯង [...][99]

38. វិធាន ១០៩ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងសវនាការចែង*ក្នុងចំណោមនោះ*ថាៈ

១. សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូលអាចធ្វើសេចក្ដីសម្រេចពិចារណាលើបណ្ដឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីតែប៉ុណ្ណោះ។

២. ការិយាល័យរដ្ឋបាលត្រូវធានាអំពីការផ្សព្វផ្សាយជាសាធារណៈអំពីសវនាការលើបណ្ដឹងសាទុក្ខ

[...]

៤. សហចៅក្រមរបាយការណ៍ត្រូវអានរបាយការណ៍ជូនអង្គជំនុំជម្រះ។ បន្ទាប់មកប្រធានត្រូវប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួនដែលមានចែងក្នុងវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង និងដឹកនាំដំណើរការសវនាការ។ ម្ចាស់បណ្ដឹងសាទុក្ខអាចធ្វើសារណាបញ្ជាក់អំពីមូលដ្ឋាននៃបណ្ដឹងសាទុក្ខ ហើយភាគីដទៃទៀតក៏អាចធ្វើសារណាឆ្លើយតបបានដែរ។ ចៅក្រមទាំងអស់អាចសួរសំណួរទាំងឡាយដែលខ្លួនយល់ថា អាចឈានទៅដល់ការធ្វើសេចក្ដីវិនិច្ឆ័យចំពោះបណ្ដឹងសាទុក្ខ។

៥. គ្រប់ករណីទាំងអស់ ជនជាប់ចោទត្រូវនិយាយក្រោយគេបំផុត។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានតបដោយសង្ខេប។

39. ត្រង់ចំណុចពាក់ព័ន្ធនៃវិធាន ២១ នៃវិធានផ្ទៃក្នុងចែងថាៈ

---

[98] មាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

[99] មាត្រា ៣៥ ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

១. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមានត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក) ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ

[...]

គ) អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី និង

ឃ) ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវ [...] មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន

[...]

៤. ការសម្រេចលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលសមស្រប។

40. វិធាន ២៣ នៃវិធានផ្ទៃក្នុងចែងថា គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. គួរឱ្យកត់សម្គាល់ គឺដើម្បី"ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់"[100]។

41. វិធាន ១២ *ស្ទួន*នៃវិធានផ្ទៃក្នុងចែង*ក្នុងនោះ*ថា អង្គភាពជនរងគ្រោះត្រូវ៖ "ជួយសម្រួល និងគាំពារដល់ការចូលរួមនៅក្នុងនីតិវិធីតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យបណ្តឹងក្នុងកិច្ចដំណើរការនីតិវិធីតុលាការ"[101]។

42. អនុលោមតាមវិធាន ៩ នៃវិធានផ្ទៃក្នុង ការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការ៖

---

[100] វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង ។

[101] វិធាន ១២ *ស្ទួន* (១)(ជ) នៃវិធានផ្ទៃក្នុង។

១. [...] ជួយគាំទ្រដល់ការបំពេញការងាររបស់អង្គជំនុំជម្រះ ការិយាល័យសហព្រះរាជអាជ្ញា [...] និងទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល និងផ្តល់សេវាកម្ម [...]

២. [...] សុវត្ថិភាពអង្គជំនុំជម្រះវិសាមញ្ញ [...]

៣. [...] ត្រូវផ្តល់សម្ភារៈ ការគ្រប់គ្រងអគារ គ្រឿងបរិក្ខារបច្ចេកទេស ព័ត៌មានវិទ្យា ភស្តុភារ យានជំនិះ មធ្យោបាយធ្វើដំណើរ និងសេចក្តីត្រូវការផ្នែករូបវន្ត និងរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ [...]

៤. ដោយមិនធ្វើឱ្យប៉ះពាល់ដល់អំណាចរបស់ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះក្នុងការទទួល និងផ្តល់ឱ្យនូវព័ត៌មាន និងបង្កើតច្រកទំនាក់ទំនងក្នុងការអនុវត្តន៍ការងាររបស់ខ្លួន ការិយាល័យរដ្ឋបាលត្រូវបំពេញភារកិច្ចជាច្រកទំនាក់ទំនងផ្លូវការទាំងផ្នែកខាងក្នុង និងខាងក្រៅរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ការិយាល័យរដ្ឋបាលត្រូវបង្កើតផ្នែកកិច្ចការសាធារណៈ ដែលត្រូវមានភារកិច្ចផ្សព្វផ្សាយព័ត៌មាន ដល់សាធារណៈជនអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

៥. ការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលការបណ្តុះបណ្តាលដល់បុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ និងជួយគាំទ្រដល់ការបណ្តុះបណ្តាលរបស់អង្គភាពយុត្តាធិការតាមតម្រូវការ។

43. វិធាន ១២ នៃវិធានផ្ទៃក្នុង ចំណុចពាក់ព័ន្ធចែងថា ការិយាល័យរដ្ឋបាលត្រូវផ្តល់ផងដែរ "នូវការគាំពារផ្នែករដ្ឋបាលដែលចាំបាច់ដល់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី"។

44. វិធាន ១២ *ស្ទួនពីរ*(១) ចែងថា "សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវធានាឱ្យមានប្រសិទ្ធភាពអំពីការរៀបចំតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឱ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការចាំបាច់សម្រាប់ការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័សក្នុងបរិបទពិសេសរបស់ អ.វ.ត.ក."។

45. ចុងក្រោយ វិធានផ្ទៃក្នុងចែងថា សវនាការគប្បីត្រូវប្រព្រឹត្តទៅជាសាធារណៈ និងថា "ការិយាល័យរដ្ឋបាលត្រូវធានាការផ្សព្វផ្សាយជាសាធារណៈនៃសវនាការ តែត្រូវគោរពដល់វិធានការការពារនានា ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ [...]"[102]។

---

[102] វិធាន ៧៩(៦) និង ១០៤ *ស្ទួន* នៃវិធានផ្ទៃក្នុង។

# ការពិភាក្សា

## *សំអាងហេតុសម្រាប់សេចក្តីសម្រេចលើសំណើសុំពន្យារពេល*

46. គ្រប់ភាគីយល់ស្របលើសារៈសំខាន់ និងភាពជាប់ពាក់ព័ន្ធនៃសំណួរដែលបានលើកឡើងក្នុងសំណើសុំពន្យារពេល និងជាពិសេសថា សវនាការផ្ទាល់ជាជម្រើសល្អប្រសើរ[103]។ ជាឯកច្ឆន្ទ ភាគីបានស្នើសុំការផ្តល់ដំណឹងឱ្យបានឆាប់រហ័ស បើទោះបីមិនផ្លូវការក៏ដោយ អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំពន្យារពេល ព្រមទាំងសំណួររបស់អង្គជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[104]។ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២១ អង្គជំនុំជម្រះបានទទួលសំណើសុំពន្យារពេល សេចក្តីសង្កេតរបស់មេធាវីការពារក្តី ការជូនដំណឹងមិនផ្លូវការនូវការឆ្លើយតបរបស់សហព្រះរាជអាជ្ញា និងជំហរបស់ការិយាល័យរដ្ឋបាលត្រៀមលក្ខណៈរួចរាល់ជួយគាំទ្រអង្គជំនុំជម្រះ។

47. ដោយឃើញថា ការត្រៀមលក្ខណៈរបស់ភាគីសម្រាប់សវនាការដែលបានគ្រោងទុក រួមបញ្ចូលទាំងការធ្វើដំណើរដែលជិតនឹងកើតមានជាលក្ខណៈអន្តរជាតិដូចបានលើកឡើងដោយមេធាវីការពារក្តី អង្គជំនុំជម្រះបានជូនដំណឹងភាគីថា អង្គជំនុំជម្រះបានសម្រេចលុបចោលសវនាការនៅថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១។ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ អង្គជំនុំជម្រះជាផ្លូវការបានជូនដំណឹងភាគីថា សវនាការត្រូវបានផ្អាកដោយសារស្ថានភាពជំងឺកូវីដ-១៩ ក្នុងប្រទេសកម្ពុជា[105]។ ហេតុដូច្នេះ អង្គជំនុំជម្រះផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរពេញលេញដូចខាងក្រោម។

---

[103] សំណើសុំពន្យារពេល កថាខណ្ឌ ២២, ៣១-៣៦, ៥០។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។ សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ១៥-១៦, ៥០, ៦៣-៦៥។ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើទម្រង់បែបបទ កថាខណ្ឌ ៣, ៥, ១៤(២)។ សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៣០-៣១។

[104] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។ សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៦៨ (iii) និង (iv)។ សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ១១។ សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ, កថាខណ្ឌ ១៦, ១៩-២០, ៣១។

[105] សេចក្តីជូនដំណឹងទាក់ទងទៅនឹងសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F62។

48. កាលបរិច្ឆេទសវនាការដំបូងមុនថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា គឺគ្រោងធ្វើក្នុងខែមករា ឆ្នាំ ២០២១ ដែលនាពេលនោះ ស្ថានភាពជំងឺកូវីដ-១៩ អាចគ្រប់គ្រងបានក្នុងប្រទេសកម្ពុជា[106]។ អស់រយៈពេលបួនខែកន្លងមក ស្ថានភាពក្នុងប្រទេសមានលក្ខណៈធ្ងន់ធ្ងរយ៉ាងគំហុកបន្ទាប់ពីផ្ទុះការឆ្លងរាលដាលក្នុងសហគមន៍ នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១[107]។

49. ជាការឆ្លើយតប រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការការពារមួយចំនួន រួមមានប្រតិបត្តិការចាក់ថ្នាំបង្ការភ្លាមៗ ការធ្វើចត្តាឡីស័ក ១៤ ថ្ងៃនៅពេលចូលមកប្រទេសកម្ពុជា និងបែងចែក"តំបន់ក្រហម"ជាចំណុចក្តៅនៃជំងឺកូវីដ-១៩ ទូទាំងប្រទេសកម្ពុជា ដោយមានការដាក់របាំងបិទផ្លូវមិនឱ្យឆ្លងកាត់ និងចេញពីផ្ទះ ដោយទទួលជំនួយជាកញ្ចប់ពីកងទ័ព។ វិធានការបង្ការទាំងនេះបង្ហាញពីភាពប្រឈមផ្នែកភស្តុភារយ៉ាងខ្លាំងក្នុងការបើកសវនាការនៅក្នុងខែ ឧសភា ជាពិសេស ក្នុងការសម្រួលតាមការចង់បានរបស់ភាគីសម្រាប់ការធ្វើសវនាការចូលរួមផ្ទាល់ក្នុងកម្រិតមួយដែលអាចធ្វើទៅបាន ការដំឡើង និងការធ្វើតេស្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការចូលរួមពីចម្ងាយ ការជួយសម្រួលវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការរៀបចំឱ្យមេធាវីការពារក្តីអាចទំនាក់ទំនងជាមួយ ខៀវ សំផន។ បន្ថែមលើនេះ ការបំពេញការងារពីចម្ងាយ បានអនុវត្តចាប់តាំងពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០ រហូតដល់បច្ចុប្បន្ន[108]។

---

106 សេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ F58។

107 *សូមមើលឧទាហរណ៍* របាយការណ៍ទូត*កម្ពុជាបង្ហាញការកើនឡើងជំងឺកូវីដ-១៩ យ៉ាងខ្លាំងបន្ទាប់ពីជនជាតិចិនរត់ចេញពីចត្តាឡីស័ក* ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១។ ខ្មែរថែម(Khmer Times) *ឧប្បត្តិហេតុក្នុងសហគមន៍ថ្ងៃទី ២០ ខែ កុម្ភៈ ពាក់ព័ន្ធនឹងតំបន់ក្តៅនៃជំងឺកូវីដ-១៩* ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២១។ ព័ត៌មាន Al Jazeera *កូវីដប្រភេទថ្មីនៃប្រទេសអង់គ្លេស បានរុញច្រានកម្ពុជាមកដល់មាត់នៃសោកនាដកម្មជាតិ* ១៥ ខែ មេសា ២០២១។

108 សេចក្តីប្រកាសរបស់ UNAKRT ចំណងជើងថា "ការបំពេញការងារជាជម្រើសក្នុងបរិបទនៃជំងឺកូវីដ-១៩" ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០។ សូមមើលផងដែរសេចក្តីប្រកាសរបស់ UNAKRT ចំណងជើងថា "ការបន្តការបំពេញការងារជាជម្រើសរហូតដល់ និងរួមបញ្ចូលថ្ងៃអាទិត្យ ទី ១៤ ខែ មីនា ឆ្នាំ" ថ្ងៃទី ០៨ ខែ មេសា ២០២១។ សេចក្តីប្រកាសរបស់ UNAKRT ចំណងជើងថា "កូវីដ-១៩ ការបន្តការបំពេញការងារជាជម្រើសរហូតដល់ និងរួមបញ្ចូលថ្ងៃអាទិត្យ ទី ០៩ ខែ ឧសភា ឆ្នាំ ២០២១" ថ្ងៃទី ០៨ ខែ មេសា ២០២១។ សេចក្តីប្រកាសរបស់ UNAKRT ចំណងជើងថា "កូវីដ-១៩ - ការបន្តការបំពេញការងារជាជម្រើសរហូតដល់ និងរួមបញ្ចូលថ្ងៃអាទិត្យ ទី ០៦ ខែ មិថុនា ឆ្នាំ ២០២១" ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០២១។ សេចក្តីប្រកាសរបស់ UNAKRT ចំណងជើងថា "កូវីដ-១៩ - ការបន្តការបំពេញការងារជាជម្រើស" ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២១។

50. មុនពេលឈានដល់ការសម្រេចផ្អាកសវនាការ អង្គជំនុំជម្រះបានពិចារណាលើអត្ថប្រយោជន៍យុត្តិធម៌ សុចរិតភាព ភាពត្រឹមត្រូវ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់ជនជាប់ចោទភាគីក្នុងការទទួលបានការជំនុំជម្រះបានឆាប់រហ័ស[109]។ អង្គជំនុំជម្រះក៏បានពិចារណាផងដែរលើកាលៈទេសៈជាអាទិភាពក្នុងរាជធានីភ្នំពេញ ដូចជា ក្តីបារម្ភអំពីសុខភាពសាធារណៈ សុវត្ថិភាព និងសុខុមាលភាពអ្នកដែលជួយសម្រួល និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងស្ថានភាពអាក្រក់នៃការរាតត្បាតជំងឺកូវីដ-១៩ ក្នុងកម្ពុជា ព្រមទាំងការលំបាកជាក់លាក់ដែលបានលើកឡើងដោយភាគីដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ការធ្វើបទបង្ហាញនៃរឿងក្តី និងអត្ថប្រយោជន៍រៀងៗខ្លួន។ ក្នុងចំណោមនោះ មានក្តីបារម្ភពីរដែលមានលក្ខណៈពិសេសសម្រាប់អង្គជំនុំជម្រះធ្វើការពិចារណា។

51. ទីមួយ ភាពមិនប្រាកដប្រជាជុំវិញវិធានការផ្សេងៗ និងការជួយសម្រួលវត្តមានដើមបណ្តឹងរដ្ឋប្បវេណីពេលសវនាការ។ ដូចមានចែងក្នុងវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីស្នូលនៃកិច្ចដំណើរការនីតិវិធី ហើយតុលាការគប្បីធានាថា សិទ្ធិរបស់ពួកគាត់ត្រូវបានគោរព[110]។ អនុលោមតាមវិធាន ១២ *ស្ទួន* និង*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដែលផ្តល់សេចក្តីទុកចិត្តលើសហមេធាវីនាំមុខក្នុងការរៀបចំការតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី និងស្របតាមឋានៈក្នុងកិច្ចដំណើរការនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាភាគីទៅនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. និងសិទ្ធិជាក់លាក់ក្នុងការចូលរួមនីតិវិធី អង្គជំនុំជម្រះមានភារកិច្ចធានាថា សិទ្ធិរបស់ពួកគាត់ត្រូវបានគោរពដើម្បីការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងមូល។ ដូច្នេះ នៅពេលពិចារណាឃើញថា ពុំមានការប្រមូលផ្តុំជាក្រុមត្រូវបានអនុញ្ញាតដោយច្បាប់ និងបានពិចារណាទៅលើសុវត្ថិភាពសាធារណៈ និងអ្នកចូលរួមសវនាការ អង្គជំនុំជម្រះចាត់ទុកថា ជាការសំខាន់ដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវមានវត្តមានពេលសវនាការតាមកម្រិតដែលធ្វើទៅបាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះចាត់ទុកថាជាការចាំបាច់បំផុតដែលមធ្យោបាយបន្ថែមដូចជាការភ្ជាប់ទំនាក់ទំនងប្រព័ន្ធសោតទស្សន៍ និង/ឬ កិច្ចការសាធារណៈត្រូវបានជួយសម្រួលដោយការិយាល័យរដ្ឋបាលទទួលបន្ទុកផ្សព្វផ្សាយព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានយល់ដឹង និងចូលរួមជាអតិបរមា។

---

[109] មាត្រា ៣៥ ថ្មី (គ) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។ វិធាន ១២ *ស្ទួនបី* (១) និង ២១ (៤) នៃវិធានផ្ទៃក្នុង។

[110] វិធាន ២១(១)(គ)នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ វិធាន ១២ *ស្ទួន* នៃវិធានផ្ទៃក្នុង ។

52. ទីពីរ អង្គជំនុំជម្រះពិចារណាលើការប្រឈម(ឥឡូវត្រូវបានដោះស្រាយ)របស់ ខៀវ សំផន និងសហមេធាវីការពារក្តីរបស់គាត់ក្នុងការទំនាក់ទំនងក្រោយពីមានការរឹតបន្តឹងដោយសារជំងឺកូវីដ-១៩ ដែលបានរារាំងមេធាវីមិនអាចធ្វើដំណើរទៅមន្ទីរឃុំឃាំង អ.វ.ត.ក.។ ទាក់ទងនឹងបញ្ហានេះ ដូចបានបង្ហាញដោយមេធាវីការពារក្តីអំពីការលំបាកក្នុងការទំនាក់ទំនងជាមួយ ខៀវ សំផន ដោយសារការរឹតត្បិតនេះ និងនត្ថិភាពនៃឧបករណ៍សម្រាប់ទំនាក់ទំនងក្នុងមន្ទីរឃុំឃាំង អង្គជំនុំជម្រះបង្គាប់ឱ្យដំឡើងឧបករណ៍នេះដើម្បីអាចទំនាក់ទំនងនៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២១[111]។ បើទោះបីជាការិយាល័យរដ្ឋបាលបានផ្តល់របាយការណ៍អំពីការបញ្ចប់ការដំឡើងដោគជ័យ និងការតេស្តសាកល្បងឧបករណ៍ នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២១ ក៏ដោយ[112] ក៏ឃើញថា សហមេធាវីការពារក្តីរបស់ ខៀវ សំផន អាចទំនាក់ទំនងមានប្រសិទ្ធភាពជាមួយ ខៀវ សំផន នៅក្នុងសប្តាហ៍បន្ទាប់ ដែលមានរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះនៅមុនការគ្រោងបើកសវនាការលើកដំបូង។ ជាក់ស្តែង ខៀវ សំផន និងសហមេធាវីរបស់គាត់ពុំអាចទំនាក់ទំនងគ្នាបានអស់ជាច្រើនសប្តាហ៍មុនពេលគ្រោងសវនាការ។ ការប្រឈមក្នុងការទំនាក់ទំនងនេះបានធ្វើឱ្យក្តីរំពឹងទុកក្នុងការអនុវត្តន៍តាមសវនាការគ្រោងទុកនោះ *ជាក់ស្តែង* គ្មានប្រសិទ្ធភាព។

53. បញ្ហាទាំងពីរនេះ ដែលមានលក្ខណៈចាំបាច់ចំពោះភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី បូករួមជាមួយនឹងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ ដែលពុំធ្លាប់មានក្នុងប្រទេសកម្ពុជា និងផលវិបាកមកលើភាគី តម្រូវឱ្យមានការពន្យារពេលសវនាការ។ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះទទួលយកសំណើសុំនេះ។

## ***ការពិចារណាលើទម្រង់បែបបទនៃសវនាការ***

54. ផ្អែកលើក្តីបារម្ភពាក់ព័ន្ធទៅនឹងការអនុវត្តតាម"ការព្យាករណ៍នៃរឿងក្តីបច្ចុប្បន្ន និងក្តីរំពឹងរបស់សាធារណជន" ការិយាល័យរដ្ឋបាលបានលើកជាគំនិតឱ្យធ្វើជាសារណាលាយលក្ខណ៍អក្សរជំនួសការ

[111] ដីកាបង្គាប់មន្ទីរឃុំឃាំងឱ្យអនុញ្ញាតបុគ្គលិក UNARKT/ECCC ផ្នែក ICT ចូលក្នុងមន្ទីឃុំឃាំងដំឡើងឧបករណ៍ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២១ ឯកសារលេខ F64។

[112] ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ របាយការណ៍យោងតាម ឯកសារលេខ F63 ស្តីពីការដំឡើងឧបករណ៍ក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក. ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២១ ឯកសារលេខ F64។

ដេញដោលផ្ទាល់មាត់ក្នុងកាលៈទេសៈដែលអង្គជំនុំជម្រះពិចារណាឃើញថា ការបើកសវនាការក្នុងខែឧសភា ពុំអាចធ្វើទៅបាននោះ[113]។ ភាគីទាំងអស់បានជំទាស់ការលើកសំណើនេះ[114]។

55. អង្គជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងបានចែងដោយឥតព្រលាំអំពីការបើកសវនាការបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[115]។ មានតែក្នុងករណីនៃបណ្តឹងសាទុក្ខភ្លាមៗប៉ុណ្ណោះ ដែលវិធានផ្ទៃក្នុងបានអនុញ្ញាតឱ្យធ្វើការសម្រេចផ្អែកលើសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ[116]។ ក្រៅតែពីបទប្បញ្ញត្តិនេះ អង្គជំនុំជម្រះពុំជឿជាក់ថា សារណាជាលាយលក្ខណ៍អក្សរជំនួសសារណាផ្ទាល់មាត់ បំពេញតាមគោលបំណងនៃសវនាការឡើយ ជាពិសេសនៅពេលពិចារណាលើសារណាបណ្តឹងសាទុក្ខដែលមានទំហំធំ ត្រូវបានដាក់រួចរាល់ហើយចំពោះមុខអង្គជំនុំជម្រះចំនួនសរុប ១.៤០០ ទំព័រ។ អង្គជំនុំជម្រះពិចារណាឃើញបន្ថែមទៀតថា ការពន្យារពេលពុំបានប៉ះពាល់ដល់ការព្យាករណ៍ដែលបានគ្រោងទុកក្នុងការបញ្ចប់សំណុំរឿងនេះ។ ការលើកជាគំនិតបែបនេះពុំមានលក្ខណៈជាប់ពាក់ព័ន្ធឡើយ នៅពេលធ្វើការធានាអំពីការគោរពសិទ្ធិរបស់ភាគី និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់ការិយាល័យរដ្ឋបាល។

56. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា គ្រប់ភាគីបានយល់ស្របថា ការចូលរួមសវនាការដោយផ្ទាល់ជាជម្រើសមួយល្អប្រសើរ។ ទោះជាយ៉ាងណាក្តី វិសាលភាពនៃការចូលរួមនេះអាស្រ័យលើស្ថានភាពជំងឺកូវីដ-១៩ ក្នុងរាជធានីភ្នំពេញ និងអត្ថិភាពនៃការចាក់ថ្នាំបង្ការក្នុងទ្រង់ទ្រាយធំ និងការគ្រោងកាលបរិច្ឆេទសវនាកាឡើងវិញ។ អង្គជំនុំជម្រះទទួលស្គាល់ថា មានក្តីបារម្ភខ្លាំងពីសំណាក់ការិយាល័យរដ្ឋបាលដែលថាសវនាការចូលរួមផ្ទាល់ពេញលេញពុំមានសុវត្ថិភាពឡើយ។ ចៅក្រមអង្គជំនុំជម្រះតុលាការកំពូលក្នុងពេលពិនិត្យបន្ទប់សវនាការបានកត់សម្គាល់ឃើញថា ក្នុងបន្ទប់បិទជិតគ្រប់ជ្រុងទាំងបីគ្មានបង្អួចអាចបើកឱ្យចរន្តខ្យល់ពីខាងក្រៅចេញចូលបាន ដោយសាររូបសណ្ឋាននៃបន្ទប់សវនាការតូចចង្អៀតដែលជាបញ្ហាចម្បង។ បញ្ហាសំខាន់មួយទៀត គឺថា ប្រព័ន្ធម៉ាស៊ីនត្រជាក់បច្ចុប្បន្នមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្សុទ្ធខ្យល់ក្នុង

---

[113] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៤។

[114] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើទម្រង់បែបបទ កថាខណ្ឌ ១៣។ សេចក្តីសង្កេតរបស់មេធាវីការពារក្តីលើទម្រង់បែបបទ កថាខណ្ឌ ៧-៩។ សេចក្តីសង្កេតរបស់សហមេធាវីនាំមុខស្តីពីទម្រង់បែបបទ កថាខណ្ឌ ៦១-៦២។

[115] វិធាន ១០៩ នៃវិធានផ្ទៃក្នុង ។

[116] វិធាន ១០៩(១) នៃវិធានផ្ទៃក្នុង។

បន្ទប់ដែលដាក់មនុស្សច្រើននាក់បាន អាស្រ័យហេតុនេះ ពុំមានលទ្ធភាពគ្រប់គ្រាន់ដែលអាចរារាំងហានិភ័យនៃការរាលដាលឆ្លងជំងឺកូវីដ-១៩ តាមខ្យល់បានឡើយ។

57. អាស្រ័យហេតុនេះ បើទោះបីជាមានការអនុវត្តន៍នូវវិធានការកាត់បន្ថយហានិភ័យ និងការកែសម្រួលបន្ទប់សវនាការតាមរបៀបណាមួយដែលអាចឱ្យសមាសភាពចូលរួមផ្ទាល់បានខ្លះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនៅតែពិចារណាឃើញថា វត្តមានក្នុងបន្ទប់សវនាការគប្បីត្រូវកម្រិតត្រឹមតែអង្គជំនុំជម្រះប៉ុណ្ណោះ។ សវនាការគប្បីត្រូវធ្វើឡើងតាមរយៈលក្ខណៈចម្រុះ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ ១៩ ជាអប្បបរមា ដែលមានតែចៅក្រម ក្រឡាបញ្ជី មន្ត្រីច្បាប់អង្គជំនុំជម្រះ និងបុគ្គលិកជំនួយចាំបាច់ដែលត្រូវបានអនុញ្ញាតដោយប្រធានអង្គជំនុំជម្រះថា នឹងត្រូវមានវត្តមានក្នុងបន្ទប់សវនាការក្នុងពេលសវនាការ ហើយគ្រប់ភាគីនឹងត្រូវចូលរួមតាមលក្ខណៈពីចម្ងាយ។

58. មកទល់ពេលនេះ ការិយាល័យរដ្ឋបាលបាន និងកំពុងរៀបចំជួយយ៉ាងសកម្ម*ក្នុងចំណោមនោះ* ការិយាល័យបានទទួលកម្មវិធីកុំព្យូទ័រសោតទស្សន៍ ដែលអាចអនុញ្ញាតឱ្យមានការចូលរួមសវនាការពីចម្ងាយ បានចែករំលែករបាយការណ៍វាយតម្លៃពីខាងក្រៅជាមួយភាគី និងអង្គជំនុំជម្រះ បានបញ្ជាក់ថា សេវាការបកប្រែ និងប្រតិចារឹកត្រៀមរួចរាល់សម្រាប់ប្រតិបត្តិការ ប៉ុន្តែត្រូវជូនដំណឹងយ៉ាងតិចប្រាំមួយសប្តាហ៍មុន បានកែសម្រួលបន្ទប់សវនាការជារូបវន្តតាមអនុសាសន៍នៅក្នុងរបាយការណ៍វាយតម្លៃពីខាងក្រៅ បានដំឡើងប្រព័ន្ធសោតទស្សន៍ក្នុងបន្ទប់សវនាការ និង"បានសាកល្បងគ្រាប់សវនាការដោយជោគជ័យ"ព្រមទាំងការផ្តល់នូវ"ការហ្វឹកហាត់ប្រើប្រាស់កម្មវិធីកុំព្យូទ័រនេះដល់អ្នកចូលរួមពីចម្ងាយមួយសប្តាហ៍មុខពេលសវនាការ"[117]។

59. ទោះជាយ៉ាងណាក្តី ដូចបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខ បញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងក្នុងសំណើសុំពន្យារពេល នៅពុំទាន់ដោះស្រាយ ឬដោះស្រាយពុំទាន់បានចប់សព្វគ្រប់នៅឡើយក្នុងការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល របាយការណ៍នៃការវាយតម្លៃពីខាងក្រៅ ឬសេចក្តីជូនដំណឹងអំពីការត្រៀមលក្ខណៈរួចរាល់របស់ផ្នែកគ្រប់គ្រងតុលាការ។ ក្តីបារម្ភទាំងនេះ ព្រមទាំងសេចក្តី

---

[117] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៧-៩។ សេចក្តីជូនដំណឹងរបស់ CMS ស្តីពីភាពរួចរាល់។

សង្កេតរបស់មេធាវីការពារក្ដី និងសហព្រះរាជអាជ្ញា ចាំបាច់ត្រូវមានការដោះស្រាយពីការិយាល័យរដ្ឋបាល[118]។

60. បន្ថែមលើនេះ ការិយាល័យរដ្ឋបាលត្រូវរៀបចំផ្ដល់ការហ្វឹកហាត់ដល់ភាគី និងអង្គជំនុំជម្រះលើកម្មវិធីកុំព្យូទ័រប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ ហើយបន្ទាប់មកត្រូវធ្វើតេស្ដសាកល្បងជាមួយអ្នកចូលរួមសវនាការទាំងអស់ឱ្យបានយ៉ាងតិច ២១ ថ្ងៃមុនពេលចាប់ផ្ដើមសវានាការ។ អង្គជំនុំជម្រះពិចារណាឃើញថា វិធានការទាំងនេះជាការចាំបាច់ក្នុងការធានាថា សវនាការអាចដំណើរការទៅប្រកបដោយអត្ថន័យក្នុងកម្រិតល្អប្រសើរតាមដែលអាចធ្វើទៅបាន។

## ផ្នែកសម្រេចសេចក្ដី÷

61. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសម្រេច៖

**ទទួលយក**សំណើសុំពន្យារពេល

**បង្គាប់**ថា សវនាការបណ្ដឹងសាទុក្ខនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៦ ដល់ ២៧ ខែ សីហា ឆ្នាំ ២០២១ តាមរយៈទម្រង់បែបបទជាលក្ខណៈចម្រុះ៖

(i) សវនាការត្រូវតែធ្វើឡើងឱ្យបានពេញលេញក្នុងបរិវេណនៃ អ.វ.ត.ក.

(ii) មានតែចៅក្រម ក្រឡាបញ្ជី បុគ្គលិករបស់អង្គជំនុំជម្រះ និងបុគ្គលិកជំនួយការចាំបាច់ដែលត្រូវបានអនុញ្ញាតដោយប្រធាន មានវត្តមានក្នុងបន្ទប់សវនាការ

(iii) គ្រប់ភាគីត្រូវចូលរួមពីចម្ងាយតាមបន្ទប់ប្រជុំរៀងៗខ្លួននៅក្នុងបរិវេណនៃ អ.វ.ត.ក.

(iv) ក្នុងករណីពុំអាចធ្វើដំណើរមកប្រទេសកម្ពុជាបាន ការចូលរួមសវនាការអាចធ្វើពីចម្ងាយ

(v) ជនជាប់ចោទត្រូវចូលរួមពីចម្ងាយចេញពីមន្ទីរឃុំឃាំង ឬបន្ទប់ផ្ទាល់ដីក្រោមបន្ទប់សវនាការនៅ អ.វ.ត.ក. និងអាចទំនាក់ទំនងជាមួយមេធាវី និង/ឬតុលាការ ឬអាស្រ័យលើអនុសាសន៍របស់ក្រុមវេជ្ជសាស្ត្រ ជនជាប់ចោទអាចអង្គុយនៅបន្ទប់ប្រជុំដែលបានរៀបចំជាមួយក្រុមមេធាវីការពារក្ដីក្នុងបរិវេណនៃ អ.វ.ត.ក.

**បង្គាប់**ការិយាល័យរដ្ឋបាល៖

---

[118] សេចក្ដីសង្កេតរបស់មេធាវីការពារក្ដីលើទម្រង់បែបបទ កថាខណ្ឌ ១១, ១៥-១៦, ១៩-២៦, ៣១។

(i) ដោយផ្អែកតាមពិធីការនៃការការពារជំងឺកូវីដ-១៩ ត្រូវជួយសម្រួលកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងសាទុក្ខឱ្យបានសមស្រប

(ii) ត្រូវសម្របសម្រួលវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ ដោយធ្វើការពិភាក្សាជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

(iii) រៀបចំផ្តល់ការហ្វឹកហាត់គ្រប់គ្រាន់ដល់អ្នកចូលរួមសវនាការទាំងអស់ ឱ្យដឹងស្គាល់ពីប្រព័ន្ធសោតទស្សន៍ ហើយបន្ទាប់មកត្រូវធ្វើតេស្តសាកល្បងដំណើរការគួរជាទីពេញចិត្តរបស់ភាគី អង្គជំនុំជម្រះ ការបកប្រែ ព័ត៌មានវិទ្យា និងបុគ្គលិកសន្តិសុខ យ៉ាងតិច ២១ ថ្ងៃ មុនពេលសវនាការ និង

(iv) ត្រូវផ្តល់ជំនួយការរៀបចំចាំបាច់ដល់ភាគីទាំងអស់សម្រាប់សវនាការ។

**រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**